# អនុសញ្ញាសិទ្ធិកុមារ

ច្បាប់ទាំងនេះត្រូវប្រើប្រាស់លើកុមារទាំងអស់ ដោយមិនគិតពីអាយុ ភេទ ជំនឿសាសនា ពិការភាព ឬប្រវត្តិគ្រួសារឡើយ*



## យើងមានសិទ្ធិ...

1. និយាយអ្វីដែលយើងគិតថាមានឥទ្ធិពលមកលើយើង។ មនុស្សគ្រប់គ្នាគួរស្តាប់ពួកយើង និងយកគំនិតរបស់ពួកយើងទៅធ្វើការពិចារណា។



2. មានឈ្មោះមួយ និងសញ្ជាតិមួយ
3. នៅពេលធ្វើការសម្រេចចិត្តអំពីកុមារណាម្នាក់ មនុស្សគ្រប់រូបគួរជ្រើសរើសឧត្តមប្រយោជន៍ដែលល្អបំផុតសម្រាប់កុមារម្នាក់នោះ។
4. បង្ហាញពីគំនិត មនសិការ និងជំនឿសាសនារបស់ពួកគេ។
5. ចូលរួមក្នុងការប្រជុំ និងការរៀបចំផ្សេងៗ។
6. មានភាពឯកជនដោយគ្មានការរំខាន។
7. ទទួលព័ត៌មានអំពីប្រធានបទផ្សេងៗ រួមបញ្ចូលទាំងអំពីខ្លួនរបស់ពួកយើង។
8. ទទួលបានការថែរក្សាទាំងផ្នែករាងកាយ និងសុខភាព។



9. ទៅសាលារៀន។
10. ដើម្បីមានកម្រិតជីវភាពដ៏ល្អមួយ។
11. លេង និងធ្វើសកម្មភាពកំសាន្តមួយចំនួន។
12. ទទួលបានបរិស្ថានបរិសុទ្ធ មានសុវត្ថិភាព និងសុខភាពល្អ។
13. កុមារពិការត្រូវទទួលបានការជួយជ្រោមជ្រែងឲ្យរស់នៅក្នុងជីវិតដ៏ពេញលេញ និងរស់រវើក ព្រមទាំងក្លាយជាមនុស្សឯករាជតាមតែអាចធ្វើបាន។
14. ទទួលបានការការពារពីគ្រួសាររបស់យើង និងការរំលោភបំពាន ឬការប្រមាថ។
15. ទទួលបានការការពារពីថ្នាំញៀនគ្រោះថ្នាក់ទាំងឡាយ។



16. មានការការពារប្រឆាំងនឹងទាសភាព ការចាប់បង្ខំ ឬការជួញដូរ។
17. ទទួលបានការការពារប្រឆាំងនឹងការងារដែលមានគ្រោះថ្នាក់ ឬការងារដែលមិនសមរម្យសម្រាប់អាយុរបស់យើង។
18. ទទួលបានការការពារនៅពេលមានសង្គ្រាម។
19. ការពារខ្លួនរបស់យើង ប្រសិនបើគេចោទប្រកាន់ថាយើងបានធ្វើបទល្មើសអ្វីមួយ។
20. ហើយចុងក្រោយ យើងមានសិទ្ធិទទួលបានសិទ្ធិទាំងនេះពីមនុស្សរស់នៅជុំវិញយើង ពីគ្រួសាររបស់យើង ពីមិត្តភក្តិរបស់យើង ពីរាជរដ្ឋាភិបាល និងសង្គម។



ដោយសេចក្តីស្មោះត្រង់ពី,

សិស្សទាំងឡាយនៅក្នុងសាលានេះ



* សិទ្ធិទាំងនេះគឺជាសេចក្តីសង្ខេបចេញពីអត្ថបទដើមដែលអាចរកបាននៅលើគេហទំព័រ http://www.vcao.org.kh/